ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៨៩៩០ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ១៨.....ខែ..វិច្ឆិកា...ឆ្នាំ ២០១៦

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧ គិតត្រឹមថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ មានដូចតទៅ ÷

**I. លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ ÷**

១- ការងារដាំដុះ ÷

ក- ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៣ ០០១ ០៨៥ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោក្របីចំនួន ២៦៥ ១០២ហ.ត (ស្មើនឹង ៨,៨៣%) និងដោយគ្រឿងយន្តកសិកម្មចំនួន ២ ៧៣៥ ៩៨៣ហ.ត (ស្មើនឹង ៩១,១៧%) តិចជាងឆ្នាំមុន៥៥២ ៨០២ហ.ត។

ខ- សាបសម្រេចបានចំនួន ៥០ ៦១៩ហ.ត តិចជាងឆ្នាំមុន ២០ ៤៥៤ហ.ត។

គ- ស្ទូងនិងព្រោះសម្រេចបានចំនួន ២ ៥៩៧ ៤១២ហ.ត ស្មើនឹង ១០៤,៨៨%នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន៣៦ ៦៦០ហ.ត ស្មើនឹង ៥,១៣%។

២- ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៦ (ដូចមានតារាងជូនភ្ជាប់)÷

ការងារប្រមូលផលស្រូវរដូវវស្សា រហូតមកដល់ពេលនេះ សម្រេចបានចំនួន ៦៦២ ៨៣៣ហ.ត លើផ្ទៃដីអនុវត្តសរុប ២ ៥៩៧ ៤១២ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ២ ១២៥ ៧៧៦តោន លើសឆ្នាំមុន ៧៦៧ ០២១តោន។ ទិន្នផលគិតជាមធ្យម ៣,២០៧តោន/ហ.ត (សប្តាហ៍មុន ៣,៥៧២តោន/ហ.ត) លើសឆ្នាំមុន ២២៦គ.ក្រ/ហ.ត។

**II. ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧** (ដូចមានតារាងជូនភ្ជាប់)÷

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ១២០ ៥៩៩ហ.ត តិចជាងឆ្នាំមុនចំនួន ៥៨ ៤១៣ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន ៥ ២១៧ហ.តស្មើនឹង ៤,៣៣% និងដោយគ្រឿងយន្តចំនួន ១១៥ ៣៨២ហ.តស្មើនឹង ៩៥,៦៧%
- សាបបានសរុបចំនួន ១៥៦ហ.ត តិចជាងឆ្នាំមុនចំនួន ៤៩៧ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន ៧៧ ៤២៦ហ.ត ស្មើនឹង ១៨,០៣%នៃផែនការ ៤២៩ ៣៥៥ហ.ត តិចជាងឆ្នាំមុន ៥២ ០៣០ហ.ត។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 , Preah Norodom Sangkat Tonle Basak Khan Chamkamon B V D, Phnom Penh. Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 217-320

**III.ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧** (ដូចមានតារាងជូនភ្ជាប់)÷

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ៧ ០៣៤ហ.ត ស្មើនឹង ៩,៦០% នៃផែនការ ៧៣ ២៤៩ហ.ត លើសឆ្នាំមុន ១ ៧១៣ ហ.ត។

ខ -ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន ៩១២ហ.ត ស្មើនឹង ៦,៤៦% នៃផែនការ ១៤ ១២១ហ.ត តិចជាងឆ្នាំមុន ៣៦១ហ.ត។

## IV. សេចក្តីសន្និដ្ឋាន

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបាន ២ ៥៩៧ ៤១២ហត ស្មើនឹង ១០៤,៨៨% នៃផែនការ ២ ៤៧៦ ៤៤៦ហត លើសឆ្នាំមុនចំនួន ៤៥ ៨៩៨ហត។ មកទល់ពេលនេះ ប្រជាកសិករ បាននិងកំពុងជំរុញការងារប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះ ល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង ២៥,៥២% នៃផ្ទៃដីអនុវត្ត ២ ៥៩៧ ៤១២ហត ដែលទទួលបានទិន្នផលគិតជាមធ្យម ៣,២០៧តោន/ហ.ត និងកំពុងខិតខំបន្តជំរុញការដាំដុះដំណាំរដូវប្រាំងជាបន្តទៅទៀត។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានណែនាំដល់ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់ត្រូវចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ព្រមទាំងជំរុញការជីកស្តារ ស្រះប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ។ ម្យ៉ាងទៀតក្នុងកាលៈទេសៈដែលកសិករកំពុងតែប្រមូលផលស្រូវចុងរដូវវស្សានេះ ក៏មានការបន្ទាបតម្លៃស្រូវនៅលើទីផ្សារដែលធ្វើឱ្យប៉ះពាល់ទៅលើចំណូលរបស់កសិករផងដែរ។ ដូច្នេះមន្ទីរ អង្គភាពជំនាញពាក់ពន្ធ័ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន សហគមម៉ាស៊ីនកិនស្រូវ និងសហគមន៍កសិកម្មក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមទាំងអស់នេះ ដែលអាចកើតឡើងជាយថាហេតុនៅពេលខាងមុខ ព្រមទាំងការអនុវត្តតាមស្មារតីនៃលិខិតលេខ៩៤២ សជណ.កស របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦។ ដោយឡែក ក្រសួងបន្តចុះពិនិត្យតាមដានការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចាត់ក្រុមអន្តរាគមន៍ចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្តជាប់ជាប្រចាំ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ចម្លងជូន ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ ២០១៦

(គិតត្រឹមថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 247,015 | 89,618 | 3.176 | 284,611 | 36.28 | 17-11-2016 |
| 02 | បាត់ដំបង | 289,567 | 91,724 | 3.886 | 356,475 | 31.68 | 16-11-2016 |
| 03 | កំពង់ចាម | 89,861 | 15,947 | 3.609 | 57,560 | 17.75 | 10-11-2016 |
| 04 | កំពង់ឆ្នាំង | 124,409 | 3,200 | 2.952 | 9,447 | 2.57 | 16-11-2016 |
| 05 | កំពង់ស្ពឺ | 115,116 | 1,566 | 2.743 | 4,295 | 1.36 | 18-09-2016 |
| 06 | កំពង់ធំ | 215,526 | 53,783 | 2.573 | 138,381 | 24.95 | 17-11-2016 |
| 07 | កំពត | 138,388 | 22,651 | 3.712 | 84,078 | 16.37 | 10-10-2016 |
| 08 | កណ្តាល | 35,329 | 9,181 | 3.762 | 34,542 | 25.99 | 26-10-2016 |
| 09 | កោះកុង | 10,503 | 1,601 | 2.756 | 4,412 | 15.24 | 16-11-2016 |
| 10 | ក្រចេះ | 33,072 | 14,057 | 3.170 | 44,561 | 42.50 | 14-11-2016 |
| 11 | មណ្ឌលគិរី | 23,608 | 2,295 | 2.776 | 6,371 | 9.72 | 18-11-2016 |
| 12 | ភ្នំពេញ | 10,291 | 147 | 3.020 | 444 | 1.43 | 27-09-2016 |
| 13 | ព្រះវិហារ | 82,398 | 17,161 | 2.780 | 47,707 | 20.83 | 11-11-2017 |
| 14 | ព្រៃវែង | 270,111 | 50,158 | 3.617 | 181,408 | 18.57 | 16-11-2016 |
| 15 | ពោធិ៍សាត់ | 115,984 | 67,863 | 3.123 | 211,936 | 58.51 | 17-11-2016 |
| 16 | រតនគិរី | 24,011 | 13,627 | 2.200 | 29,979 | 56.75 | 17-11-2016 |
| 17 | សៀមរាប | 186,735 | 57,565 | 2.470 | 142,186 | 30.83 | 17-11-2016 |
| 18 | ព្រះសីហនុ | 16,605 | 1,575 | 1.834 | 2,888 | 9.49 | 15-11-2016 |
| 19 | ស្ទឹងត្រែង | 28,678 | 16,025 | 2.500 | 40,062 | 55.88 | 16-11-2016 |
| 20 | ស្វាយរៀង | 168,528 | 31,511 | 3.000 | 94,533 | 18.70 | 16-11-2016 |
| 21 | តាកែវ | 197,444 | 55,478 | 4.076 | 226,128 | 28.10 | 16-11-2016 |
| 22 | ឧត្តរមានជ័យ | 86,501 | 33,289 | 2.495 | 83,049 | 38.48 | 15-11-2016 |
| 23 | កែប | 3,597 | 621 | 3.240 | 2,012 | 17.26 | 15-11-2016 |
| 24 | ប៉ៃលិន | 5,825 | 133 | 2.504 | 333 | 2.28 | 10-11-2016 |
| 25 | ត្បូងឃ្មុំ | 78,310 | 12,057 | 3.183 | 38,378 | 15.40 | 11-11-2016 |
| សរុប | | **2,597,412** | **662,833** | **3.207** | **2,125,776** | **25.52** | |
| តួលេខសប្តាហ៍មុន | | **2,597,412** | **401,229** | **3.572** | **1,433,286** | **15.45** | |
| តួលេខឆ្នាំ២០១៥ | | **2,560,752** | **455,820** | **2.981** | **1,358,755** | **17.80** | |
| ប្រៀបធៀបឆ្នាំមុន | | **36,660** | **207,013** | **0.226** | **767,021** | **7.72** | |

បានឃើញនិងឯកភាព
ជ. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

## លឿនការងារបច្ចុបន្ទោកផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ )

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃភ្ជួររាស់ សរុប (ហ.ត) | គោ-ក្របី ហ.ត | គោ-ក្របី % | គ្រឿងយន្ត ហ.ត | គ្រឿងយន្ត % | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) សន្ទូង | ពង្រោះ | សរុប | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 17,870 | 7,880 | - | - | 7,880 | 100.00 | 1 | 30 | 7,757 | 7,787 | 43.58 | 17-11-2016 |
| 02 | បាត់ដំបង | 12,000 | - | | - | | - | | | | - | - | |
| 03 | កំពង់ចាម | 42,000 | 9,943 | 2,496 | 25 | 7,447 | 75 | 70 | 254 | 7,802 | 8,056 | 19.18 | 10-11-2015 |
| 04 | កំពង់ឆ្នាំង | 30,700 | 971 | - | - | 971 | 100.00 | - | - | 971 | 971 | 3.16 | 16-11-2016 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | | | | - | - | |
| 06 | កំពង់ធំ | 36,000 | 4,747 | - | - | 4,747 | 100.00 | 9 | 125 | 4,613 | 4,738 | 13.16 | 17-11-2016 |
| 07 | កំពត | 7,000 | - | | - | | - | | | | - | - | |
| 08 | កណ្តាល | 55,800 | 2,432 | 763 | 31 | 1,669 | 69 | - | - | 1,324 | 1,324 | 2.37 | 17-11-2016 |
| 09 | កោះកុង | - | - | | - | | - | | | | - | - | |
| 10 | ក្រចេះ | 14,000 | 14,370 | 1,444 | 10.05 | 12,926 | 89.95 | 21 | 62 | 7,971 | 8,033 | 57.38 | 14-11-2016 |
| 11 | មណ្ឌលគិរី | | - | | - | | - | | | | - | - | |
| 12 | ភ្នំពេញ | 1,150 | - | - | - | - | - | - | - | - | - | - | |
| 13 | ព្រះវិហារ | 130 | - | | - | | - | | | | - | - | |
| 14 | ព្រៃវែង | 75,000 | 10,237 | - | - | 10,237 | 100.00 | - | - | 10,237 | 10,237 | 13.65 | 16-11-2016 |
| 15 | ពោធិសាត់ | 9,000 | 2,210 | - | - | 2,210 | 100.00 | - | - | 1,053 | 1,053 | 11.70 | 16-11-2016 |
| 16 | រតនៈគិរី | | - | | - | | - | | | | - | - | |
| 17 | សៀមរាប | 20,925 | 7,135 | - | - | 7,135 | 100 | | | 3,780 | 3,780 | 18.06 | 17-11-2016 |
| 18 | ព្រះសីហនុ | | - | | - | | - | | | | - | - | |
| 19 | ស្ទឹងត្រែង | 100 | - | | - | | - | | | | - | - | |
| 20 | ស្វាយរៀង | 20,000 | 20,000 | - | - | 20,000 | 100.00 | - | - | 20,000 | 20,000 | 100.00 | 16-11-2016 |
| 21 | តាកែវ | 75,000 | 37,319 | 364 | 0.98 | 36,955 | 99.02 | - | - | 8,387 | 8,387 | 11.18 | 15-11-2016 |
| 22 | ឧត្តរមានជ័យ | 600 | - | | - | | - | | | | - | - | |
| 23 | កែប | 30 | - | | - | | - | | | | - | - | |
| 24 | ប៉ៃលិន | 1,000 | - | | - | | - | | | | - | - | |
| 25 | ត្បូងឃ្មុំ | 10,500 | 3,355 | 150 | 4.47 | 3,205 | 95.53 | 55 | 135 | 2,925 | 3,060 | 29.14 | 11-11-2016 |
| | **សរុប** | **429,355** | **120,599** | **5,217** | **4.33** | **115,382** | **95.67** | **156** | **606** | **76,820** | **77,426** | **18.03** | |
| | **តួលេខសប្តាហ៍មុន** | **429,355** | **74,012** | **2,692** | **3.64** | **71,320** | **96.36** | **77** | **125** | **33,565** | **33,690** | **7.85** | |
| | **តួលេខឆ្នាំមុន** | **417,325** | **179,012** | **4,590** | **2.56** | **174,422** | **97.44** | **653** | **2,036** | **127,420** | **129,456** | **31.02** | |
| | **ប្រៀបធៀបឆ្នាំមុន** | **12,030** | **-58,413** | **627** | **1.76** | **-59,040** | **-1.76** | **-497** | **-1,430** | **-50,600** | **-52,030** | | |

បានឃើញនិងឯកភាព
ក. ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

# ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 225 | - | | | 6,250 | | - | | 1,325 | 159 | 120 | | 7,920 | 159 | 2.01 |
| 02 | បាត់ដំបង | 460 | | | | | | 50 | | 960 | | 300 | | 1,770 | - | - |
| 03 | កំពង់ចាម | 1,010 | 150 | 614 | 155 | 20 | | 760 | 89 | 2,380 | 763 | 150 | 318 | 4,320 | 1,784 | 41.30 |
| 04 | កំពង់ឆ្នាំង | 1,090 | 170 | | | 90 | | 230 | | 1,860 | | 1,800 | | 5,070 | - | - |
| 05 | កំពង់ស្ពឺ | 4 | - | | | 0 | | 0 | | 190 | | 0 | | 194 | - | - |
| 06 | កំពង់ធំ | 130 | - | | | 90 | | 60 | | 345 | | 20 | | 645 | - | - |
| 07 | កំពត | 200 | - | | | 135 | | 245 | | 590 | | 255 | | 1,425 | - | - |
| 08 | កណ្តាល | 8,101 | 6,620 | | | 225 | | 190 | | 5,056 | | 4,307 | | 17,879 | - | - |
| 09 | កោះកុង | 27 | - | | | 3 | | 5 | | 60 | | - | | 95 | - | - |
| 10 | ក្រចេះ | 1,800 | 1,700 | 639 | 413 | - | | 80 | | 420 | 132 | 40 | 8 | 2,340 | 779 | 33.29 |
| 11 | មណ្ឌលគិរី | - | - | | | - | | - | | - | 474 | - | | - | 474 | - |
| 12 | ភ្នំពេញ | 130 | - | | | - | | - | | 342 | | - | | 472 | - | - |
| 13 | ព្រះវិហារ | - | - | | | - | | - | | 782 | | - | | 782 | - | - |
| 14 | ព្រៃវែង | 1,825 | 1,825 | | | 200 | | 10 | | 790 | | 1,425 | | 4,250 | - | - |
| 15 | ពោធិ៍សាត់ | 200 | 100 | 38 | | 850 | 34 | 350 | | 500 | 59 | 300 | 3 | 2,200 | 134 | 6.09 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | 830 | - | | | 2,490 | | 265 | | 2,040 | | 1,850 | | 7,475 | - | - |
| 18 | ព្រះសីហនុ | 35 | | | | 140 | | 20 | | 175 | | | | 370 | - | - |
| 19 | ស្ទឹងត្រែង | 250 | - | 81 | | - | | - | 25 | 450 | 59 | 500 | | 1,200 | 165 | 13.75 |
| 20 | ស្វាយរៀង | | | | | 7,100 | | 110 | | 1,170 | | - | | 8,380 | - | - |
| 21 | តាកែវ | 232 | - | 109 | - | 398 | 1,698 | 110 | 397 | 648 | 842 | - | 169 | 1,388 | 3,215 | 231.63 |
| 22 | ឧត្តរមានជ័យ | 9 | - | | | 0 | | - | | 65 | | - | | 74 | - | - |
| 23 | កែប | 150 | 30 | | | 30 | | 100 | | 200 | | - | | 480 | - | - |
| 24 | ប៉ៃលិន | 2,005 | 2,000 | 298 | - | 1,500 | | | | 15 | | 1,000 | 26 | 4,520 | 324 | 7.17 |
| 25 | ត្បូងឃ្មុំ | 5,210 | 8,942 | 110 | 85 | - | | 400 | | 1,145 | 40 | 490 | 5 | 10,977 | 155 | 13,097 |
| | **សរុប** | **18,713** | **12,595** | **1,779** | **568** | **19,521** | **1,732** | **2,585** | **511** | **11,350** | **2,488** | **12,067** | **524** | **73,249** | **7,034** | **9.60** |
| | **តួលេខសប្តាហ៍មុន** | **18,713** | **12,595** | **937** | **278** | **19,521** | **1,725** | **2,585** | **397** | **11,350** | **987** | **12,067** | **197** | **73,249** | **4,243** | **5.79** |
| | **តួលេខឆ្នាំមុន** | **10,504** | **188** | **2,129** | **402** | **4,174** | **214** | **4,116** | **277** | **11,804** | **1,920** | **12,100** | **781** | **42,698** | **5,321** | **12.46** |
| | **ប្រៀបធៀបឆ្នាំមុន** | **8,209** | **12,407** | **-350** | **166** | **15,347** | **1,518** | **-1,531** | **234** | **-454** | **568** | **-33** | **-257** | **30,551** | **1,713** | **-2.86** |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | - | | - | | - | | 110 | | - | | - | | 110 | - | - |
| 02 | បាត់ដំបង | 100 | | | | 100 | | 30 | | | | | | 230 | - | - |
| 03 | កំពង់ចាម | 790 | 107 | - | | 30 | 378 | 360 | | - | | 3,380 | | 4,560 | 485 | 10.64 |
| 04 | កំពង់ឆ្នាំង | 80 | | | | 760 | | 60 | | 10 | | 60 | | 970 | - | - |
| 05 | កំពង់ស្ពឺ | 48 | | - | | - | | - | | - | | - | | 48 | - | - |
| 06 | កំពង់ធំ | 199 | | - | | - | | - | | - | | - | | 199 | - | - |
| 07 | កំពត | 205 | | - | | 30 | | 235 | | - | | - | | 470 | - | - |
| 08 | កណ្តាល | 96 | | 50 | | 150 | | 442 | | - | | - | | 738 | - | - |
| 09 | កោះកុង | - | | - | | - | | 340 | | - | | - | | 340 | - | - |
| 10 | ក្រចេះ | 120 | 5 | - | - | - | - | 110 | 89 | - | - | - | - | 230 | 94 | 40.87 |
| 11 | មណ្ឌលគិរី | - | | - | | - | | - | | - | | - | | - | - | - |
| 12 | ភ្នំពេញ | - | | - | | | | | | | | | | - | - | - |
| 13 | ព្រះវិហារ | - | | - | | - | | - | | - | | - | | - | - | - |
| 14 | ព្រៃវែង | 130 | | - | | 1,025 | | 175 | | - | | - | | 1,330 | - | - |
| 15 | ពោធិ៍សាត់ | 550 | | 50 | | 200 | | 720 | 20 | - | | - | | 1,520 | 20 | 1.32 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | - | | 10 | | 210 | | 405 | | - | | - | | 625 | - | - |
| 18 | ព្រះសីហនុ | | | | | | | 40 | | | | | | 40 | - | - |
| 19 | ស្ទឹងត្រែង | - | | - | | | | | | | | | | - | - | |
| 20 | ស្វាយរៀង | | | | | | | 523 | | | | | | 523 | - | - |
| 21 | តាកែវ | 122 | 71 | - | | 11 | 17 | 175 | 220 | - | - | - | - | 308 | 308 | 100.00 |
| 22 | ឧត្តរមានជ័យ | - | | - | | - | | - | | - | | - | | - | - | - |
| 23 | កែប | 100 | | - | | - | | 30 | | - | | - | | 130 | - | - |
| 24 | ប៉ៃលិន | 50 | | | 5 | 100 | | 10 | | | | | | 160 | 5 | 3.13 |
| 25 | ត្បូងឃ្មុំ | 230 | | - | | - | | 20 | | - | | 1,340 | | 1,590 | - | - |
| | **សរុប** | **3,624** | **183** | **110** | **5** | **2,616** | **395** | **3,785** | **329** | **10** | **-** | **4,780** | **-** | **14,121** | **912** | **6.46** |
| | **តួលេខសប្តាហ៍មុន** | **3,624** | **71** | **110** | **5** | **2,616** | **17** | **3,785** | **301** | **10** | **-** | **4,780** | **-** | **14,121** | **394** | **2.79** |
| | **តួលេខឆ្នាំមុន** | **3,624** | **278** | **1,173** | **610** | **2,789** | **168** | **3,735** | **109** | **80** | **-** | **8,930** | **108** | **20,331** | **1,273** | **6.26** |
| | **ប្រៀបធៀបឆ្នាំមុន** | **-** | **-95** | **-1,063** | **-605** | **-173** | **227** | **50** | **220** | **-70** | **-** | **-4,150** | **-108** | **-6,210** | **-361** | **0.20** |

បានឃើញ និងឯកភាព

ភ្នំពេញ, ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៦

ន.- ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

ប្រធានការិយាល័យស្ថិតិ